ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៥ ដោយ អគ្គនាយកដ្ឋានពន្ធដារ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែមីនា និងប្រចាំត្រីមាសទី១ឆ្នាំ២០១៥

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែមីនា និងប្រចាំត្រីមាសទី១ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយឯកឧត្តម **ជុំ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមលោកស្រីអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។



ជាកិច្ចចាប់ផ្តើមឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសំដែងអំណរសាទរជាមួយថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំខែមីនានិងប្រចាំត្រីមាសទី១ឆ្នាំ២០១៥ និងជំរុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារសមាជិក អង្គប្រជុំដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែង និងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៥។

ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានរាយការណ៍អំពីស្ថានភាពចំណូលពន្ធដារ មានដូចជា÷ ក្នុងខែមីនា ឆ្នាំ២០១៥ នេះ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទ បានចំនួន ៩១៧ ៥៦០ លានរៀល (គិតជាដុល្លារប្រមាណ ២២៩,៣៩ លានដុល្លារ) និងបានធ្វើបែបបទបង់ចូលថវិកាជាតិ ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ បានចំនួន **៦៣២ ១៦២ លានរៀល** (គិតជាដុល្លារប្រមាណ **១៥៨,១ លានដុល្លារ**)។ ដោយឡែក ចំពោះចំណូលពន្ធដែលនៅសល់ចំនួន ២៨៥,៣៩៨ លានរៀល អគ្គនាយកដ្ឋានពន្ធដារកំពុងធ្វើបែបបទ បង់ចូលរតនាគារជាតិ និងកត់ត្រាយោងជាចំណូលសម្រាប់ខែមេសា ឆ្នាំ២០១៥។ ប្រសិនបើប្រៀបធៀបទៅនឹងចំណូលពន្ធសម្រាប់ខែមីនា ឆ្នាំ២០១៤ ឃើញថា ការប្រមូលចំណូលពន្ធដារហើយបានបង់ចូលថវិកាជាតិ ក្នុងខែមីនា ឆ្នាំ២០១៥ បានចំនួន **៦៣២ ១៦២ លានរៀល** នេះ មានការកើនឡើង ស្មើនឹង ៨២,៦៧%។

សម្រាប់ត្រីមាសទី១ឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធផ្ទៃក្នុងបានចំនួន **១ ២៩៣ ៦៥៩ លានរៀល** (គិតជាដុល្លារប្រមាណ **៣២៣,៤១ លានដុល្លារ**) **ស្មើនឹង ២៧,៧៦ %** នៃគោលដៅកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលក្នុងនោះរួមមាន ថវិកាថ្នាក់ជាតិប្រមូលបានចំនួនស្មើនឹងប្រមាណ **២៨០,៨៥ លានដុល្លារ** និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ បានចំនួនស្មើនឹងប្រមាណ **៤២,៥៧ លានដុល្លារ**។

ប្រសិនបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៤ ឃើញថា ការប្រមូលចំណូលពន្ធដារបង់ចូលថវិកាជាតិ សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៥ នេះ **កើនឡើងចំនួន** ស្មើនឹង ៤៨,៥៣%។

ក្នុងរយៈពេលដូចគ្នានៃឆ្នាំ២០១៤ និងត្រីមាសទី១ ឆ្នាំ២០១៥ ឃើញថា ក៏មានការកើនឡើងនូវចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗមួយចំនួន ដូចជា ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ៥៧,៨% ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ២៩,២% អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ៤២,៧% និងអាករពិសេសមានការកើនឡើងប្រមាណ ២៦,៧%។

បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៤និងត្រីមាសទី១ ឆ្នាំ២០១៤ ចំណូលពន្ធតាមសកម្មភាពអាជីវកម្ម មានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន÷ ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ៣៣,៩% ផលិតភេសជ្ជៈកើនឡើងប្រមាណ ១៩,៧% ទូរគមនាគមន៍កើនឡើងប្រមាណ ២៩,៩% នីហរ័ណអាហរ័ណកើនឡើងប្រមាណ ២១,៧% សណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ៣៤,៥% ផលិតថ្នាំជក់កើនឡើងប្រមាណ ១០៨,៩% ផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ១៣,៩% អាកាសយានដ្ឋាននិងកំពង់ផែកើនឡើងប្រមាណ ៦,៥% លក់ភេសជ្ជៈកើនឡើងប្រមាណ ៦២,១% លក់សម្ភារការិយាល័យកើនឡើងប្រមាណ ៥៥,៥% ផលិតម្ហូបអាហារកើនឡើងប្រមាណ ១៨,០% ផលិតយានយន្តកើនឡើងប្រមាណ ១៧៧,៤% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ១២,៩% និងផលិតគ្រឿងចក្រកើនឡើងប្រមាណ ៧២,៣%។

ក្នុងអង្គប្រជុំឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានលើកឡើងថា អគ្គនាយកដ្ឋានពន្ធដារ ជាអង្គភាពអនុវត្តគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាលក្នុងការប្រមូលចំណូលចូលថវិកាជាតិ និងជាអង្គភាពបម្រើសេវាសាធារណៈជូនអ្នកជាប់ពន្ធឱ្យបានល្អប្រសើរ ឱ្យមានការពេញចិត្តក្នុងការបង់ពន្ធពីអ្នកជាប់ពន្ធ។ ហើយឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា ១)ពិនិត្យនិងពិភាក្សាលើរបាយការណ៍លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែមីនានិងប្រចាំត្រីមាសទី១ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានពន្ធដារ និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៥។ ២)ការប្រមូលពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៤ និងការប្រមូលពន្ធប៉ាតង់សម្រាប់ឆ្នាំ២០១៥។ ៣) រៀបចំផែនការកែទម្រង់អភិវឌ្ឍស្ថាប័នរយៈពេល ៥ ឆ្នាំ និងរយៈពេល ៣ ឆ្នាំ រំកិល។ ៤) ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យមរបស់អគ្គនាយកដ្ឋានពន្ធដារ។ ៥) ជំរុញបង្កើនល្បឿនការកែលម្អ ការរៀបចំបង្កើតជាបញ្ជរបម្រើសេវាអ្នកជាប់ពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ។ ៦) ពង្រឹងការចាត់អាជីវកម្មដ្ឋានជាប់ពន្ធតាមរបបមៅការទៅរបបស្វ័យប្រកាស ដែលកំពុងមានសកម្មភាពអាជីវកម្មនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ។ ៧) ជំរុញការរៀបចំបញ្ជីការគណនេយ្យពន្ធដារសម្រាប់អ្នកជាប់ពន្ធតាមស្តង់ដារ តាមប្រភេទទំហំសហគ្រាស។ ៨) បន្តជំរុញការចុះបញ្ជីសហគ្រាសតាមប្រព័ន្ធថ្មីនិងការធ្វើបច្ចុប្បន្នភាពសហគ្រាស។ ៩) រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា (IT) សម្រាប់ការចែករំលែកព័ត៌មាន (Information sharing)

ពីសាខាពន្ធដារខេត្ត-ខណ្ឌមកអគ្គនាយកដ្ឋានពន្ធដារ និងរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សសម្រាប់អគ្គនាយកដ្ឋានពន្ធដារ។១០) បន្តរៀបចំពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកផ្នែកព័ត៌មានវិទ្យា ផ្នែកវិវាទ ផ្នែកវិភាគនិងព្យាករណ៍ចំណូលជាដើម។ ១១) បន្តជំរុញការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងពន្ធដារដល់អ្នកជាប់ពន្ធទាំងឡាយ។ ១២) ជំរុញការផ្តល់ការលើកទឹកចិត្តដល់មន្ត្រីពន្ធដារ ដែលបានខិតខំបំពេញការងារប្រមូលចំណូលពន្ធជាពិសេសប្រមូលចំណូលពន្ធសម្រាប់ឆ្នាំ២០១៥ និងបណ្តាឆ្នាំបន្តបន្ទាប់។ ១៣) បន្តជំរុញដំណើរការនៃការចរចាកិច្ចព្រមព្រៀងចៀសវាងការយកពន្ធត្រួតគ្នា (DTA)។

ទន្ទឹមនេះ ក្នុងគោលដៅដើម្បីធានាបាននូវភាពជឿទុកចិត្ត ព្រមទាំងបង្កើននូវប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនអ្នកជាប់ពន្ធ ឲ្យកាន់តែល្អប្រសើរ នាឱកាសនោះដែរ ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកាត់ខ្សែបូរសម្ពោធដាក់ឲ្យប្រើប្រាស់និងចុះពិនិត្យមើលនូវបញ្ជរ(Counter) សម្រាប់ទទួលលិខិតប្រកាសពន្ធ ទទួលពន្ធប្រថាប់ត្រា ការធ្វើបច្ចុប្បន្នភាពចុះបញ្ជីសហគ្រាសតាមប្រព័ន្ធថ្មី កិច្ចការរដ្ឋបាល (លិខិតចេញ-ចូល) កន្លែងផ្តល់ព័ត៌មាន និងបញ្ជរសម្រាប់សាខាធនាគារ អេស៊ីលីដា ភីអិលស៊ី និងមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យពន្ធដារ ( Data Center) ដែលស្ថិតក្នុងអគាររបស់អគ្គនាយកដ្ឋានពន្ធដារ។

ដើម្បីប្រមូលចំណូលពន្ធឲ្យបានគ្រប់តាមផែនការកំណត់ដោយច្បាប់ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយកែទម្រង់ដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងនោះ ÷ ទី១) បន្តពង្រឹងការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី។ ទី២) ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំងអស់ដែលបានចុះបញ្ជីពន្ធដារដាក់ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Data- base) ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធ។ ទី៣) ធ្វើបច្ចុប្បន្នភាពទិន្នន័យអចលនទ្រព្យទាំងអស់ដែលបានចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ដាក់ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) របស់អគ្គនាយកដ្ឋានពន្ធដារ។ ទី៤) បន្តលើកកម្ពស់និងបញ្ជ្រាបវប្បធម៌ពន្ធដារ បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ ទាំងក្នុងចំណោមពលរដ្ឋ និងមន្ត្រីពន្ធដារ តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីប្រព័ន្ធពន្ធដារកម្ពុជា។





ជាកិច្ចបញ្ចប់ ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលដែលមានការកើនឡើងគួរជាទីពេញចិត្តបាន និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់ឯកឧត្តម អស់លោកជាថ្នាក់ដឹកនាំប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់ និងមន្ត្រីពន្ធដារទាំងអស់ ខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**អគ្គនាយកដ្ឋានពន្ធដារ**